01320150



ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Aug-2016, 09:31
CMS/CFO: Ly Bunloung

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**Declassified to Public**
**12 June 2020**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦

ភាសា ៖ អង់គ្លេស [ភាសាដើម]

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

## ដីកាសម្រេចរួមលើសំណើបន្ថែមរបស់ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះទទួលពិចារណាអំពីមោឃភាពនៃកិច្ចស៊ើបសួរអំពីវត្តតាមាក់ និងទួលបេង និងវត្តអង្គញ្ជី និងបទចោទនានាពាក់ព័ន្ធនឹងទួលបេង

**<u>ផ្ញើជូន÷</u>**

**អង្គបុរេជំនុំជម្រះ**

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេទ្ធី
Suzana TOMANOVIC

**មេធាវីតំណាង**
**ដើមបណ្តឹងរដ្ឋប្បវេណី÷**

ជេត វណ្ណលី
ហុង គីមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Bernabe NEKUI
Lyma NGUYEN
Beini YE

## I- ប្រវត្តិនីតិវិធី

1. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ និង ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

2. ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានកាន់តំណែងមុនយើង បានដាក់ អោ អាន *ក្នុងចំណោមប្រការផ្សេងៗ* ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមនុស្សឃាតដោយគិតទុកជាមុន ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅទួលបេង[1]។

3. នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥ មេធាវីការពារក្តី អោ អាន ("មេធាវីការពារក្តី") បានដាក់សំណើអនុលោមតាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង សុំឱ្យ ស.ច.ស ប្តឹងទៅអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ឱ្យទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរអំពីវត្តតាមាក់ ("សំណើសុំមោឃភាពវត្តតាមាក់")[2]។

4. ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ យើងបានចេញដីកាសម្រេចមួយដែលបានឯកភាពសំណើសុំមោឃភាពវត្តតាមាក់ ("ដីកាសម្រេចចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥")[3]។ អ.ប.ជ នាពេលបច្ចុប្បន្ន បានទទួលពិចារណាអំពីសំណើសុំមោឃភាពវត្តតាមាក់។

5. នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ មេធាវីការពារក្តីបានដាក់សំណើអនុលោមតាមវិធាន៧៦(២)នៃវិធានផ្ទៃក្នុង សុំឱ្យ ស.ច.ស ប្តឹងទៅ អ.ប.ជ ទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញដី និងបទចោទនានាទាក់ទងនឹងទួលបេង ("សំណើសុំមោឃភាពទួលបេង")[4]។

---

[1] សំណុំរឿង 00៤-D242, *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង,* ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥, ទំព័រ ៦-៧។

[2] សំណុំរឿង 00៤-D263, *សំណើសុំអង្គបុរេជំនុំជម្រះទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរអំពីវត្តតាមាក់*, ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥។

[3] សំណុំរឿង 00៤-D263/1, *ដីកាសម្រេចលើពាក្យសុំតាមវិធានផ្ទៃក្នុង ៧៦ របស់ អោ អាន សុំមោឃភាពកិច្ចស៊ើបសួរលើវត្តតាមាក់*, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥, កថាខណ្ឌ ១៦-១៧។

[4] សំណុំរឿង 00៤-D299, *សំណើសុំអង្គបុរេជំនុំជម្រះទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញដី និងបទចោទនានាទាក់ទងនឹងទួលបេង,* ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦។

6. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានជូនដំណឹង អោ អាន តាមរយៈសហមេធាវីរបស់គាត់ អំពីបទចោទបន្ថែមប្រឆាំងនឹងគាត់ ដែលបានដាក់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវបានចោទថាបានប្រព្រឹត្តនៅវត្តអង្គញ្ជី និងមន្ទីរសន្តិសុខវត្តតាមាក់ ("បទចោទបន្ថែម")[5]។

7. នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ យើងបានចេញដីកាសម្រេចមួយដែលបានទទួលយកសំណើសុំមោឃភាពទួលបេង ត្រង់ចំណុចដែលវាទាក់ទងមោឃភាពនៃកិច្ចស៊ើបសួរដែលត្រូវបានបំពេញក្នុងអំឡុងរយៈកាលនៃខែ មករា ឆ្នាំ ២០១២ ដល់ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ដូចដែលបានលើកឡើងក្នុងឧបសម្ព័ន្ធ ក នៃដីកាសម្រេចរបស់យើង និងបដិសេធផ្នែកសេសសល់នៃសំណើនេះ ("ដីកាសម្រេចចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦")[6]។ អ.ប.ជ នាពេលបច្ចុប្បន្ន ទទួលពិចារណាអំពីសំណើសុំមោឃភាពទួលបេង ក្នុងកម្រិតនៃការទទួលយកក្នុងដីកាសម្រេចចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦។

8. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្ដីបានដាក់សំណើបន្ថែមចំនួនពីរ ទាក់ទងសំណើសុំមោឃភាពវត្តតាមាក់("សំណើវត្តតាមាក់បន្ថែម")[7] និងសំណើសុំមោឃភាពទួលបេង ("សំណើទួលបេងបន្ថែម")[8]។

II. **សារណា**

9. មេធាវីការពារក្ដីលើកឡើងថាបទចោទបន្ថែមដែលចោទទៅលើ អោ អាន ទាក់ទងវត្តតាមាក់ និងវត្តអង្គញ្ជី មានកំហុសនីតិវិធី ពីព្រោះបទចោទទាំងនេះបានមកពីកិច្ចស៊ើបសួរដែលមេធាវីការពារក្ដី អះអាងក្នុងសំណើសុំមោឃភាពវត្តតាមាក់ និងសំណើសុំមោឃភាពទួលបេង ថាមានកំហុសនីតិវិធី[9]។

---

[5] សំណុំរឿង ០០៤-D303, *កំណត់ហេតុនៃការបង្ហាញខ្លួនម្ដងទៀត,* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦, ទំព័រ ៥-៦, ៧,៨។

[6] សំណុំរឿង ០០៤-D299/1, *ដីកាសម្រេចលើពាក្យសុំរបស់ អោ អាន ស្នើប្ដឹងទៅអង្គបុរេជំនុំជម្រះ សុំទទួលពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញ្ជី និងបទចោទនានាទាក់ទងនឹងទួលបេង,* ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦។

[7] សំណុំរឿង ០០៤-D263/2, *សំណើបន្ថែមទាក់ទងនឹងសំណើរបស់ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះ ទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរអំពីតាមះ,* ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦, កថាខណ្ឌ ១, ("សំណើវត្តតាមះបន្ថែម")។

[8] សំណុំរឿង ០០៤-D299/2, *សំណើបន្ថែមលើសំណើរបស់ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរលើទួលបេង និងវត្តអង្គញ្ជី និងបទចោទទាក់ទងនឹងទួលបេង,* ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦, កថាខណ្ឌ ១ ("សំណើទួលបេងបន្ថែម")។

[9] *សូមមើល* សំណើសុំមោឃភាពវត្តតាមាក់, កថាខណ្ឌ ២១-៥២។ សំណើវត្តតាមាក់បន្ថែម,កថាខណ្ឌ ១៥, ១៧។ សំណើសុំមោឃភាពទួលបេង, កថាខណ្ឌ ១៩-២៤, ៣៩-៦៥។ សំណើទួលបេងបន្ថែម, កថាខណ្ឌ ១០-១១។

10. មេធាវីការពារក្តីលើកទឡ្ហីករណ៍ថាប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបានកាន់តំណែងមុនយើង បានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋនានានៅវត្តតាមាក់ និងវត្តអង្គញ្ញដី មេធាវីការពារក្តីនឹងបានដាក់បញ្ចូលសំណើនាពេលបច្ចុប្បន្នក្នុងសំណើសុំមោឃភាពវត្តតាមាក់ និងសំណើសុំមោឃភាពទួលបេង[10]។ ហេតុដូច្នេះ មេធាវីការពារក្តីស្នើសុំឱ្យ ស.ច.ស ប្តឹងទៅ អ.ប.ជ ឱ្យទទួលពិចារណាអំពីសំណើវត្តតាមាក់បន្ថែម និងសំណើទួលបេងបន្ថែម ក្នុងបំណងបញ្ចូលគ្នាជាមួយសំណើសុំមោឃភាពវត្តតាមាក់ និងសំណើសុំមោឃភាពទួលបេង ដែលស្ថិតនៅចំពោះមុខ អ.ប.ជ នាពេលបច្ចុប្បន្ន[11]។

III. **ពិភាក្សា**

11. វិធាន៧៦(៥)នៃវិធានផ្ទៃក្នុងចែងថានៅពេល អ.ប.ជ សម្រេចទុកជាមោឃៈកិច្ចស៊ើបសួរណាមួយ អ.ប.ជ ត្រូវសម្រេចថាតើមោឃភាពនោះមានប៉ះពាល់ដល់កិច្ច ឬដីកាដទៃទៀតដែរឬទេ។ នាពេលបច្ចុប្បន្ន អ.ប.ជ បានទទួលពិចារណាសំណើសុំមោឃភាពទួលបេង និងសំណើសុំមោឃភាពវត្តតាមាក់។ ប្រសិនបើ អ.ប.ជ សម្រេចទុកជាមោឃៈកិច្ចស៊ើបសួរណាមួយក្នុងចំណោមកិច្ចស៊ើបសួរដែលត្រូវបានបំពេញទាក់ទងទីតាំងឧក្រិដ្ឋកម្មទាំងពីរនេះ អ.ប.ជ ក៏នឹងសម្រេចថាតើកិច្ច ឬដីកាដទៃទៀតណាខ្លះ រួមទាំងបទចោទនានា នឹងរងការប៉ះពាល់ពីការសម្រេចរបស់ខ្លួន។ ហេតុដូច្នេះ ពុំមានភាពចាំបាច់ដើម្បីសុំឱ្យអង្គបុរេជំនុំជម្រះទទួលពិចារណាសំណើវត្តតាមាក់បន្ថែម និងសំណើទួលបេងបន្ថែមឡើយ ពីព្រោះដំណោះស្រាយដែលបានស្នើសុំក្នុងសំណើទាំងនោះ នឹងត្រូវពិចារណាដោយ អ.ប.ជ នៅពេលពិនិត្យអំពីសុពលភាពនៃកិច្ចស៊ើបសួរលើទីតាំងឧក្រិដ្ឋកម្មទាំងពីរនេះ[12]។

12. លទ្ធផលនៃសំណើសុំមោឃភាពដែលជាមូលដ្ឋាននៃដីកាសម្រេចចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៥ នៅចំហរនៅឡើយ ហើយដូច្នេះដីកាសម្រេចនេះនាពេលបច្ចុប្បន្នពុំមែនជាអ្នកកំណត់អំពីបញ្ហានេះឡើយ។ មានតែ អ.ប.ជ ប៉ុណ្ណោះមានសិទ្ធិអំណាចសម្រេចថាតើកិច្ចណាមួយមានកំហុសនីតិវិធីដែរ ឬយ៉ាងណា។

13. អាស្រ័យហេតុនេះ យើងនឹងមិនពិចារណាបន្ថែមថាតើសំណើបន្ថែមចំនួនពីរនេះ បំពេញលក្ខខណ្ឌសម្រាប់ការបញ្ជូនទៅ អ.ប.ជ ដែរឬយ៉ាងណាឡើយ។

---

[10] សំណើវត្តតាមាក់បន្ថែម, កថាខណ្ឌ ១៧។ សំណើទួលបេងបន្ថែម, កថាខណ្ឌ ១០។

[11] សំណើវត្តតាមាក់បន្ថែម, កថាខណ្ឌ ៣។ សំណើទួលបេងបន្ថែម, កថាខណ្ឌ ២។

[12] *សូមមើល* ដីកាសម្រេចចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦, កថាខណ្ឌ ៣៥។

14. ដីកាសម្រេចនេះត្រូវបានដាក់ជាភាសាអង់គ្លេស ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសម្អាងហេតុខាងលើ យើង៖**

15. **បដិសេធ** សំណើទួលបេងបន្ថែម និងសំណើវត្តតាមាក់បន្ថែម និង

16. **ឲ្យដំណឹង** ទៅមេធាវីការពារក្តីថា អ.ប.ជ បានទទួលពិចារណារួចហើយនូវដំណោះស្រាយ ដែលបានស្នើសុំក្នុងសំណើទួលបេងបន្ថែម និងសំណើវត្តតាមាក់បន្ថែម។

កាលបរិច្ឆេទ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៦ ភ្នំពេញ

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**
**Co-juge d'instruction International**